ព្រឹទ្ធសភា

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍
# ស្ដីពី
# លទ្ធផលការងាររបស់ព្រឹទ្ធសភា
# ប្រចាំខែធ្នូ ឆ្នាំ២០១៨

នៅក្នុងខែធ្នូ ឆ្នាំ២០១៨នេះ ព្រឹទ្ធសភាបានបំពេញភារកិច្ចដូចតទៅ:

## ១.សកម្មភាពថ្នាក់ដឹកនាំព្រឹទ្ធសភា

### ១.១ សម្ដេចវិបុលសេនាភក្ដី សាយ ឈុំ ប្រធានព្រឹទ្ធសភា បាន៖

-ទទួលភារកិច្ចជាប្រមុខរដ្ឋស្ដីទីចំនួន០១លើក

-អញ្ជើញដឹកនាំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា នីតិកាលទី៤ ចំនួន ០១លើក និងប្រជុំពេញអង្គព្រឹទ្ធសភាចំនួន០២លើក

-អញ្ជើញដង្ហែព្រះរាជដំណើរ **ព្រះករុណា ព្រះបាទសម្ដេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ** នៃព្រះរាជាណាចក្រកម្ពុជា យាងបំពេញព្រះរាជទស្សនកិច្ចផ្លូវការ និងយាងនិវត្តន៍ពីសាធារណរដ្ឋសង្គមនិយមវៀតណាម នៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ

-អនុញ្ញាតជូនឯកឧត្តម Amphay KINDAVONG ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាព នៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ចូលជួបសម្ដែងការគួរសម

-អនុញ្ញាតឱ្យឯកឧត្តម Christian Rehren Bargetto ឯកអគ្គរដ្ឋទូតតែងតាំងថ្មីនៃសាធារណរដ្ឋឈីលី ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ដែលមាននិវេសនដ្ឋាននៅទីក្រុងបាងកក ចូលជួបសម្ដែងការគួរសម និងសវនាការ

-អនុញ្ញាតឱ្យឯកឧត្តម **ឃួន ផុនរតនៈ** ឯកអគ្គរដ្ឋទូតតែងតាំងថ្មីនៃព្រះរាជាណាចក្រកម្ពុជាប្រចាំនៅសាធារណរដ្ឋអេហ្ស៊ីប និងអ៊ីស្រាអែល ចូលជួបសម្ដែងការគួរសម សុំអនុសាសន៍ និងគោរពលា

-អញ្ជើញជាអធិបតី និងថ្លែងសុន្ទរកថាបើកមហាសន្និបាតតំណាងទូទាំងប្រទេសលើកទី៤ សហភាពសហព័ន្ធយុវជនកម្ពុជានៅសណ្ឋាគារសុខាភ្នំពេញ

-អញ្ជើញដឹកនាំគណៈប្រតិភូព្រឹទ្ធសភា ចូលរួមពិធីសូត្រមន្ត និងគោរពវិញ្ញាណក្ខន្ធក្នុងមិទ្ទិញខួបអនុស្សាវរីយ៍លើកទី៤០ ទិវាកំណើតរណសិរ្សសាមគ្គី អភិវឌ្ឍន៍មាតុភូមិកម្ពុជា

វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ: (855 23) 211 441, 211 442, 211 443 ទូរសារ: (855 23) 211 446, E-mail: oum_sarith@camnet.com.kh

(២ ធ្នូ ១៩៧៨-២ ធ្នូ ២០១៨) នៅវិមានអនុស្សាវរីយ៍២ធ្នូ ក្នុងភូមិជើងឃ្លូ ឃុំ២ធ្នូ ស្រុកស្នួល ខេត្តក្រចេះ

-អញ្ជើញចូលរួមជាអធិបតីពិធីមិទ្ទិញមហាជនអបអរសាទរខួបអនុស្សាវរីយ៍លើកទី៤០ ទិវាកំណើតរណសិរ្សសាមគ្គី អភិវឌ្ឍន៍មាតុភូមិកម្ពុជា(២ ធ្នូ ១៩៧៨-២ ធ្នូ ២០១៨) នៅវិមានអនុស្សាវរីយ៍២ធ្នូ ក្នុងភូមិជើងឃ្លូ ឃុំ២ធ្នូ ស្រុកស្នួល ខេត្តក្រចេះ

-អញ្ជើញជាអធិបតីក្នុងពិធីប្រារព្ធខួបលើកទី៧០ ទិវាសិទ្ធិមនុស្សអន្តរជាតិ ១០ ធ្នូ ឆ្នាំ២០១៨ ក្រោមប្រធានបទ រួមគ្នាការពារសន្តិភាពដើម្បីលើកកម្ពស់ការគោរពសិទ្ធិមនុស្ស នៅសាលមហោស្រពកោះពេជ្រ

-អញ្ជើញពិនិត្យការដ្ឋានជួសជុល និងទស្សនាប្រាសាទបន្ទាយឆ្មារ ស្ថិតនៅភូមិបន្ទាយឆ្មារ ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ

-អញ្ជើញចូលរួមប្រកួតកីឡាវាយកូនគោលពានរង្វាន់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា នៅទីលានវាយកូនគោលតារាសាគរ ខេត្តកោះកុង

-អញ្ជើញចូលរួមគោរពវិញ្ញាណក្ខន្ធសព ឯកឧត្តម **ព្រហ្ម ញាណវិចិត្រ** អតីតសមាជិកក្រុមប្រឹក្សាធម្មនុញ្ញ និងសពលោកជំទាវ **ទេស ចិន្តា** ភរិយារបស់ឯកឧត្តម **តឹក រ៉េតសំរេច** នៅសង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ

-ពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន២៣ច្បាប់ និងជ្រាបជាព័ត៌មានចំនួន៥៥ច្បាប់ ។

**១.២.ឯកឧត្តម ស៊ុំ កា អនុប្រធានទី១ព្រឹទ្ធសភា បាន :**

-ទទួលភារកិច្ចជាប្រធានស្តីទីព្រឹទ្ធសភាចំនួន០១លើក

-អញ្ជើញចូលរួមកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា នីតិកាលទី៤ ចំនួន ០៣លើក និងកិច្ចប្រជុំពេញអង្គព្រឹទ្ធសភា ចំនួន០២លើក

-អញ្ជើញចូលរួមប្រជុំពិភាក្សាការងារ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់**សម្តេច-វិបុលសេនាភក្តី សាយ ឈុំ** ប្រធានព្រឹទ្ធសភា

-អញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីបុណ្យរំលឹកខួបអនុស្សាវរីយ៍រណសិរ្ស២ធ្នូ លើកទី៤០ ទិវាកំណើតរណសិរ្សសាមគ្គី អភិវឌ្ឍន៍មាតុភូមិកម្ពុជា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់**សម្តេចអគ្គមហាពញាចក្រី ហេង សំរិន** ប្រធានរដ្ឋសភា និងជាប្រធានក្រុមប្រឹក្សាជាតិរណសិរ្សសាមគ្គី អភិវឌ្ឍន៍មាតុភូមិកម្ពុជា នៅភូមិជើងឃ្លូ ឃុំ២ធ្នូ ស្រុកស្នួល ខេត្តក្រចេះ

-អញ្ជើញចូលរួមគោរពវិញ្ញាណក្ខន្ធសពឯកឧត្តម **ព្រហ្ម ញាណវិចិត្រ** អតីតសមាជិកក្រុមប្រឹក្សាធម្មនុញ្ញនៅគេហដ្ឋានផ្ទះលេខ១១ ផ្លូវលេខ១៣៥២ សង្កាត់បឹងកេងកង១ ខណ្ឌចំការមន រាជធានីភ្នំពេញ

-ពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន០២ច្បាប់ និងជ្រាបជាព័ត៌មានចំនួន១៣ច្បាប់ ។

**១.៣.ឯកឧត្តម ខេព ឯន អនុប្រធានទី២ ព្រឹទ្ធសភា បាន** :

-អញ្ជើញចូលរួមកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា នីតិកាលទី៤ ចំនួន០៣លើក និងកិច្ចប្រជុំពេញអង្គព្រឹទ្ធសភា ចំនួន០២លើក

-អនុញ្ញាតឱ្យឯកឧត្តម Liu Jie អនុប្រធានគណៈកម្មាធិការអចិន្ត្រៃយ៍នៃសភាខេត្តស៊ីឈួន និងជាប្រធានបណ្តាញអង្គការមិនមែនរដ្ឋាភិបាលទទួលបន្ទុកកិច្ចការទំនាក់ទំនងអន្តរជាតិ ជួបសម្តែងការគួរសម និងពិភាក្សាការងារ

-អញ្ជើញជួបសំណេះសំណាលជាមួយប្រជាពលរដ្ឋ ដែលបានមកទទួលសេវាពិនិត្យ និងព្យាបាលជំងឺដោយឥតគិតថ្លៃពីក្រុមគ្រូពេទ្យស្ម័គ្រចិត្តមកពីប្រទេសបារាំង នៅភូមិគ ឃុំក្រាំងយ៉ូវ ស្រុកស្អាង ខេត្តកណ្តាល

-អញ្ជើញជប់លៀងជូនគណៈប្រតិភូខេត្តស៊ីឈួននៃសាធារណរដ្ឋប្រជាមានិតចិន នៅភោជនីយដ្ឋានចាស្មីន

-ពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន២០ច្បាប់ និងជ្រាបជាព័ត៌មានចំនួន២០ច្បាប់ ។

## ២.សម័យប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភាចំនួន០២លើក:

គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា បានប្រជុំចំនួន០២លើក ដែលមានរបៀបវារៈដូចខាងក្រោម:

១.ពិនិត្យ និងសម្រេចលើសំណើរបស់គណៈកម្មការទី២ព្រឹទ្ធសភា សុំដាក់សេចក្តីព្រាងច្បាប់ស្តីពី ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៩

២.ពិនិត្យ និងសម្រេចលើសំណើរបស់គណៈកម្មការទី២ព្រឹទ្ធសភា សុំដាក់សេចក្តីព្រាងច្បាប់ស្តីពី ការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៧

៣.ពិនិត្យ និងសម្រេចលើសំណើរបស់គណៈកម្មការទី២ព្រឹទ្ធសភា សុំដាក់សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើៈ

-កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋសង្គមនិយមវៀតណាមស្តីពី ការចៀសវាងការយកពន្ធត្រួតគ្នា និងការបង្ការការគេចវេសពន្ធពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូល

-កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋឥណ្ឌូនេស៊ីស្តីពី ការចៀសវាងការយកពន្ធត្រួតគ្នា និងការបង្ការការគេចវេសពន្ធពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូល

៤.ពិនិត្យ និងសម្រេចលើសំណើរបស់គណៈកម្មការទី៦ព្រឹទ្ធសភា សុំដាក់សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើសន្ធិសញ្ញាស្តីពី បត្យាប័នរវាងព្រះរាជាណាចក្រកម្ពុជា និងសហព័ន្ធរុស្ស៊ី

៥.ពិនិត្យសំណើរបស់រដ្ឋសភា សុំពិនិត្យ និងឱ្យយោបល់លើសេចក្តីស្នើច្បាប់ស្តីពី វិសោធនកម្មមាត្រា៤៥ថ្មី(ស្ទួន) នៃច្បាប់ស្តីពី គណបក្សនយោបាយ

៦.ពិនិត្យសំណើរបស់រដ្ឋសភា សុំពិនិត្យ និងឱ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី បរធនបាលកិច្ច

៧.កំណត់របៀបវារៈ និងកាលបរិច្ឆេទបន្តសម័យប្រជុំលើកទី២ព្រឹទ្ធសភា នីតិកាលទី៤។

**៣.សម័យប្រជុំពេញអង្គចំនួន០២លើក** :

ព្រឹទ្ធសភាប្រជុំពេញអង្គព្រឹទ្ធសភាចំនួន០២លើក ដើម្បីពិនិត្យ និងឱ្យយោបល់លើ៖

១.សេចក្តីព្រាងច្បាប់ស្តីពី ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រង ឆ្នាំ២០១៩

២.សេចក្តីព្រាងច្បាប់ស្តីពី ការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៧

៣.សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើ៖

-កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋសង្គមនិយមវៀតណាមស្តីពី ការចៀសវាងការយកពន្ធត្រួតគ្នា និងការបង្ការការគិបកេងបន្ទំពន្ធពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូល

-កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋឥណ្ឌូនេស៊ីស្តីពី ការចៀសវាងការយកពន្ធត្រួតគ្នា និងការបង្ការការគិបកេងបន្ទំពន្ធពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូល

៤.សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើសន្ធិសញ្ញាស្តីពី បត្យាប័នរវាងព្រះរាជាណាចក្រកម្ពុជា និងសហព័ន្ធរុស្ស៊ី

៥.សេចក្តីស្នើច្បាប់ស្តីពី វិសោធនកម្មមាត្រា៤៥ថ្មី(ស្ទួន) នៃច្បាប់ស្តីពី គណបក្សនយោបាយ

៦.សេចក្តីព្រាងច្បាប់ស្តីពី បរធនបាលកិច្ច ។

**៤.គណៈកម្មការជំនាញនានារបស់ព្រឹទ្ធសភា** :

ក្នុងខែធ្នូនេះ សមាជិក សមាជិកាព្រឹទ្ធសភា បានបំពេញការងារយ៉ាងសកម្មតាមតួនាទី ភារកិច្ច និងសមត្ថកិច្ចរបស់ខ្លួនប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ដូចខាងក្រោម:

### ៤.១.មុខងារនីតិកម្ម

-គណៈកម្មការជំនាញរបស់ព្រឹទ្ធសភា បានប្រជុំផ្ទៃក្នុងគណៈកម្មការ និងប្រជុំអន្តរគណៈកម្មការ ព្រឹទ្ធសភាជាមួយនឹងតំណាងរាជរដ្ឋាភិបាល និងតំណាងរាស្ត្រហត្ថលេខី ដើម្បីពិនិត្យ ពិភាក្សាលើសេចក្តីព្រាងច្បាប់ចំនួន០១ច្បាប់ និងសេចក្តីស្នើច្បាប់ចំនួន០១ច្បាប់ ។

### ៤.២.មុខងារតាមដានការអនុវត្តច្បាប់ និងគោលនយោបាយនានា

-ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៤ អញ្ជើញដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្តនៃសមាគមបេសកកម្មមនុស្សធម៌នៅកម្ពុជាចុះទៅពិនិត្យ និងព្យាបាលជំងឺជូនប្រជាពលរដ្ឋនៅខេត្តប៉ៃលិន

-អញ្ជើញចុះសិក្សាស្រាវជ្រាវប្រមូលព័ត៌មានក្នុងភូមិភាគទី៧ នៅខេត្តកោះកុង។

### ៤.៣. មុខងារតំណាង

-បានទទួលពាក្យបណ្តឹងចំនួន០៤ករណី ផ្ញើពាក្យបណ្តឹងចេញទៅក្រសួង ខេត្ត ក្រុង និងស្ថាប័នពាក់ព័ន្ធចំនួន០៨ករណី ព្រមទាំងកំពុងសិក្សាចំនួន០៣ករណី និងផ្ញើលិខិតរំលឹកជំរុញការដោះស្រាយពាក្យបណ្តឹងចំនួន០១ករណី ឆ្លើយតបទៅម្ចាស់បណ្តឹងចំនួន០៨ករណី ទទួលឯកសារពាក្យបណ្តឹងពីក្រសួង ស្ថាប័នដែលចម្លងជូនមកព្រឹទ្ធសភាជ្រាបចំនួន០៥ករណី

-អញ្ជើញចូលរួមប្រជុំពិនិត្យលទ្ធផលនៃកិច្ចប្រជុំបូកសរុប និងអនុម័តលើសេចក្តីព្រាងរបាយការណ៍ស្វ័យវាយតម្លៃការត្រួតពិនិត្យឡើងវិញនូវការអនុវត្តអនុសញ្ញា អ.ស.ប ប្រឆាំងអំពើពុករលួយ (UNCAC) និងទិសដៅបន្ត

-អញ្ជើញចូលរួមប្រជុំពិភាក្សាផែនការអនុវត្ត និងត្រៀមលក្ខណៈកិច្ចប្រជុំប្រចាំឆ្នាំលើកទី២៧ នៃវេទិកាសភាអាស៊ី-ប៉ាស៊ីហ្វិច(APPF)

-អញ្ជើញចូលរួមប្រជុំជាមួយថ្នាក់ដឹកនាំកម្មវិធីបណ្តុះបណ្តាលផ្នែកវិភាគសារពើពន្ធ (FACT/PBO) នៃវិទ្យាស្ថានសភាកម្ពុជា (PIC) ដើម្បីពិភាក្សាអំពីការត្រៀមរៀបចំសិក្ខាសាលាផ្សព្វផ្សាយលទ្ធផលនៃដំណើរទស្សនកិច្ចសិក្សារបស់គណៈប្រតិភូសមាជិកព្រឹទ្ធសភាកម្ពុជានៅប្រទេសស៊ុយអ៊ែត

-អញ្ជើញចូលរួមប្រជុំផ្ទៃក្នុងក្រុមមិត្តភាពព្រឹទ្ធសភាជាមួយក្រុមប្រឹក្សាសហព័ន្ធនៃសភាសហព័ន្ធនៃសហព័ន្ធរុស្ស៊ី

សមាជិក សមាជិកាព្រឹទ្ធសភា បានអញ្ជើញចុះទៅតាមបណ្តាខេត្ត ក្រុង និងរាជ-ធានីភ្នំពេញចំនួន៦៨លើក ដើម្បីជួបពិភាក្សាការងារ សំណេះសំណាល សាកសួរ

សុខទុក្ខប្រជាពលរដ្ឋ សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្តចុះពិនិត្យ និងព្យាបាលជំងឺជូនប្រជាពលរដ្ឋ ពិនិត្យការដ្ឋានសាងសង់ សម្ពោធសមិទ្ធផលនានា តាមដានការអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់ក្រោមជាតិ ការអនុវត្តគោលនយោបាយភូមិ ឃុំមានសុវត្ថិភាព សិក្សាឈ្វេងយល់អំពីស្ថានភាពសិទ្ធិមនុស្ស ការអនុវត្តច្បាប់ កែលម្អសេវាសាធារណៈ ពង្រឹងអភិបាលកិច្ចល្អនៅមូលដ្ឋាន និងគោលនយោបាយផ្សេងៗលើគ្រប់វិស័យ ព្រមទាំងបានចូលរួមក្នុងពិធីផ្លូវការ និងពិធីផ្សេងៗ សរុប ចំនួន៩៨លើក ។

**៥. កិច្ចសហប្រតិបត្តិការអន្តរជាតិ** :

-ឯកឧត្តម ***ឈិត គឹមយាត*** អញ្ជើញចូលរួមកិច្ចប្រជុំក្រុមប្រឹក្សាប្រតិបត្តិលើកទី២ និងមហាសន្និបាតលើកទី១១ របស់សភាតំបន់អាស៊ី APA នៅទីក្រុងអ៊ីស្តង់ប៊ុល នៃសាធារណរដ្ឋតួកគី

-ឯកឧត្តម ***អ៊ុក គង់*** អញ្ជើញចូលរួមសន្និសីទអន្តរជាតិក្រោមប្រធានបទ តួនាទីសមាជិកសភាក្នុងពិភពលោកនាពេលបច្ចុប្បន្ន និងក្រុមប្រឹក្សាសហព័ន្ធនៃសភាសហព័ន្ធនៃសហព័ន្ធរុស្ស៊ី២៥ឆ្នាំ នៃការអភិវឌ្ឍគ្រប់វិស័យ នៅទីក្រុងម៉ូស្គូ នៃសហព័ន្ធរុស្ស៊ី

-ឯកឧត្តម ***ឆាយ វណ្ណា*** អញ្ជើញចូលរួមសន្និសីទមូស្លីមអន្តរជាតិស្តីពី ការរួបរួមសាមគ្គី The Perils of Labeling and Exclusion នៅទីក្រុង Makkah នៃប្រទេសអារ៉ាប់រួម

-លោកជំទាវ ***ទី បូរ៉ាស៊ី*** និងឯកឧត្តម ***ឆាយ វណ្ណា*** អនុញ្ញាតឱ្យលោក Xavier Nuttin សមាជិកក្រុមប្រឹក្សាភិបាលជាន់ខ្ពស់ និងជាសមាជិកក្រុមប្រឹក្សាភិបាលនៃវិទ្យាស្ថានអឺរ៉ុបសម្រាប់ការសិក្សាអាស៊ី ចូលជួបសម្តែងការគួរសម ។

ថ្ងៃអង្គារ ៣កើត ខែ បុស្ស ឆ្នាំច សំរឹទ្ធិស័ក ព.ស២៥៦២

រាជធានីភ្នំពេញ, ថ្ងៃទី ៨ ខែមករា ឆ្នាំ២០១៩

**ជ.ប្រធានព្រឹទ្ធសភា**

**អនុប្រធានទី២**

**ទេព ងន**

ចម្លងជូន:

- ក្រសួងព្រះបរមរាជវាំង
- ក្រុមប្រឹក្សាធម្មនុញ្ញ
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ក្រសួងយុត្តិធម៌
- ក្រសួងព័ត៌មាន
- (ទូលថ្វាយ និងជូនជ្រាបជាព័ត៌មាន)
- កាលប្បវត្តិ-ឯកសា